ស្ថានទូតអូស្ត្រាលី
ប្រចាំព្រះរាជាណាចក្រកម្ពុជា

# សេចក្ដីប្រកាសព័ត៌មាន

*ថ្ងៃទី៣ ខែតុលា ឆ្នាំ ២០២៥*

## អបអរសាទរដល់និស្សិតដែលទើបទទួលបានអាហារូបករណ៍អូស្ត្រាលី

ថ្ងៃនេះ ឯកឧត្តម ដេវិក យីប ឯកអគ្គរដ្ឋទូតអូស្ត្រាលីប្រចាំព្រះរាជាណាចក្រកម្ពុជា បានជួបសំណេះសំណាល និងអបអរសាទរដល់និស្សិតកម្ពុជាចំនួន ៥៥ នាក់ដែលមានសមត្ថភាពខ្ពស់ និងស្នាដៃជាច្រើន ដែលត្រូវបានជ្រើសរើសបឋម ដើម្បីទទួលអាហារូបករណ៍អូស្ត្រាលី Australia Awards (AAS) សម្រាប់ឆ្នាំសិក្សា ២០២៦។ ឯកអគ្គរដ្ឋទូតបានជួបនិស្សិតទាំងនេះក្នុងថ្ងៃបើកវគ្គបណ្ដុះបណ្ដាលភាសាអង់គ្លេស នៅវិទ្យាស្ថានភាសាបរទេស នៃសកលវិទ្យាល័យភូមិន្ទភ្នំពេញ។ ក្នុងចំណោមនិស្សិតទទួលអាហារូករណ៍ទាំងនេះ មាននិស្សិតប្រាំនាក់ទទួលអាហារូបករណ៍តាមរយៈកម្មវិធីភាពជាដៃគូមេគង្គ-អូស្ត្រាលី (Mekong Australia Partnership)។

និស្សិតដែលទើបទទួលអាហារូបករណ៍ថ្មីទាំងនេះ នឹងចូលរួមជាមួយប្រជាជនកម្ពុជាប្រមាណជិត ១,១០០ នាក់ ដែលបានទៅសិក្សានៅប្រទេសអូស្ត្រាលី តាមរយៈកម្មវិធីអាហារូបករណ៍អូស្ត្រាលី និងកម្មវិធីអាហារូបករណ៍ផ្សេងៗពីមុនរបស់អូស្ត្រាលី។

ឯកអគ្គរដ្ឋទូតយីប បានមានប្រសាសន៍ថា "ការវិនិយោគលើការអប់រំដែលមានគុណភាពខ្ពស់ ទៅលើនិស្សិតកម្ពុជាដែលពូកែ និងឆ្លាត នឹងនាំមកនូវអត្ថប្រយោជន៍អភិវឌ្ឍន៍យ៉ាងសំខាន់សម្រាប់ប្រទេសជាតិ"។

"ខណៈពេលដែលកម្ពុជាកំពុងត្រៀមខ្លួនសម្រាប់ការចាកចេញពីក្រុមប្រទេសអភិវឌ្ឍន៍តិចតួច (LDCs) និងបន្តធ្វើពិពិធកម្មសេដ្ឋកិច្ច បង្កើនការវិនិយោគពីបរទេស កំណើនរឹងមាំប្រកបដោយនិរន្តរភាព និងការប្រកួតប្រជែងជាសាកល ការវិនិយោគលើធនធានមនុស្សគឺជាកត្តាចាំបាច់។ អូស្ត្រាលីកំពុងគាំទ្រប្រទេសកម្ពុជាក្នុងកិច្ចខិតខំប្រឹងប្រែងនេះ"។

"អាហារូបករណ៍អូស្ត្រាលីសម្រាប់ឆ្នាំសិក្សា ២០២៦នេះ ឆ្លុះបញ្ចាំងពីការកើនឡើងនៃបរិយាបន្នរបស់កម្មវិធី។ ច្រើនជាងពាក់កណ្ដាលនៃនិស្សិតទទួលបានអាហារូបករណ៍គឺជាស្ត្រី ហើយ ២៤% នៃនិស្សិតទទួលអាហារូបករណ៍ទទួលបានការគាំទ្រតាមរយៈកម្មវិធីមាគ៌ាសមធម៌ (Equity Pathways) ដែលរួមមាននិស្សិត ៦

នាក់ ជាជនដែលមានពិការភាព។ ក្នុងឆ្នាំនេះ ចំនួននិស្សិតទទួលអាហារូបករណ៍មកពីខាងស្ថាប័នរាជរដ្ឋាភិបាល បានកើនឡើងដល់ ៣៦% និង១៨% សម្រាប់និស្សិតទទួលអាហារូបករណ៍ដែលមកពីតាមបណ្ដាខេត្ត"។

និស្សិតទាំងនេះនឹងបន្តការសិក្សាថ្នាក់ក្រោយឧត្តមសិក្សានៅប្រទេសអូស្ត្រាលី ក្នុងវិស័យសិក្សាផ្សេងៗរួមមាន គោលនយោបាយសាធារណៈ មនុស្សយន្ត និងបញ្ញាសិប្បនិម្មិត វិទ្យាសាស្ត្រជីវវេជ្ជសាស្ត្រ ការស្ដារនីតិសម្បទា និងសុខភាពផ្លូវចិត្ត វិទ្យាសាស្ត្រទិន្នន័យ វិទ្យាសាស្ត្រវិស្វកម្ម បរិស្ថាន ការអប់រំ សន្តិភាព ជម្លោះ និងច្បាប់។ វិស័យទាំងនេះឆ្លុះបញ្ចាំងពីអាទិភាពនៃការអភិវឌ្ឍរបស់កម្ពុជា និងបង្ហាញពីការប្ដេជ្ញាចិត្តរបស់អូស្ត្រាលីក្នុងការគាំទ្រកំណើនប្រកបដោយចីរភាព និងបរិយាបន្ន។

អាហារូបករណ៍អូស្ត្រាលីជាការវិនិយោគរយៈពេលវែងសម្រាប់អនាគតរបស់កម្ពុជា។ តាមរយៈការផ្ដល់នូវជំនាញកម្រិតពិភពលោក បណ្ដាញទំនាក់ទំនង និងតម្លៃរួមដល់អ្នកដឹកនាំជំនាន់ថ្មីទាំងនេះ កម្មវិធីអាហារូបករណ៍អូស្ត្រាលីនេះកំពុងជំរុញនវានុវត្តន៍ ពង្រឹងស្ថាប័ន និងកសាងភាពជាដៃគូឲ្យកាន់តែរឹងមាំរវាងប្រទេសអូស្ត្រាលី និងកម្ពុជា។

សម្រាប់ព័ត៌មានបន្ថែមអំពីកម្មវិធីអាហារូបករណ៍អូស្ត្រាលីនៅកម្ពុជា សូមចូលទៅកាន់គេហទំព័រ www.australiaawardscambodia.org

**សម្រាប់ព័ត៌មានបន្ថែមសូមទាក់ទង៖** Media.Cambodia@dfat.gov.au